# ច្បាប់ស្តីពីការចូលរួមរបស់មាតាបិតាទូទាំងក្រសួង សម្រាប់ឆ្នាំ ២០១៤-២០១៥

*　　*　　*　　*　　*

## ផ្នែកទី I　　បំណងជាទូទៅ

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) បានសន្យាថានឹងសហការជាមួយ មាតាបិតា និង ក្រុមគ្រួសារ ហើយបានរៀបចំឲ្យមាន កម្មវិធី ការបម្រើ និង ការផ្តើមគំនិតថ្មីៗជាច្រើន ក្នុងគោលបំណងដើម្បី៖

- ការគាំទ្រដល់ទំនាក់ទំនង និងការចូលរួមរបស់មាតាបិតា នៅតាមថ្នាក់ ក្រសួង តំបន់ និង នៅតាមសាលា
- ការស្នើសុំគំនិតយោបល់ពី មាតាបិតា និង សហគមន៍ ក្នុងការធ្វើសេចក្តីសម្រេចរបស់ ក្រសួង និង សាលា
- ការពង្រីកលទ្ធភាពទទួលព័ត៌មាន និង
- ការផ្តល់ជំនួយឲ្យកាន់តែប្រសើរឡើង ក្នុងការដោះស្រាយរាល់ការបារម្ភរបស់មាតាបិតា និង ការបង្កើនសមត្ថភាពរបស់មាតាបិតា ដើម្បីធ្វើជា អ្នកដឹកនាំ និង អ្នកគាំទ្រ។

កម្មវិធីទូទាំងក្រសួង និង ការផ្តើមគំនិតថ្មីៗទាំងនេះ រួមមាន៖

- ការបង្កើនលទ្ធភាពទទួលព័ត៌មាន៖
    - ផ្តល់ព័ត៌មានអំពី កម្មវិធី ការបម្រើ វិធីសាស្រ្ត និង នីតិវិធី នៅក្នុងវ៉ិបសៃរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា www.philasd.org
    - ប្រើ ហ្វេសប៊ុក (FaceBook) និង ទ្វីតធ័រ (Twitter) ព្រមទាំងសហការជាមួយដៃគូដែលផ្តល់ព័ត៌មានតាមទម្លាប់ចាស់ ដើម្បីចែកជូនព័ត៌មានដល់ក្រុមគ្រួសារ និង សហគមន៍
    - ការអនុវត្តន៍ AskPhliaSD (http://ask.philasd.org) – ប្រព័ន្ធរៀបចំចំណេះដឹងតាមមូលដ្ឋានវ៉ិបសៃ ដែលប្រើបច្ចេកវិទ្យាដើម្បីផ្តល់ចម្លើយភ្លាមៗ ទៅនឹងសំណួរដែលគេឧស្សាហ៍សួរជាងគេ
    - ចាប់ផ្តើមប្រើ ទំព័រវ៉ិបសៃសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ (Parent and Family Portal) ដែលជាវិធីថ្មីមួយអាចឲ្យមាតាបិតាតាមដានដឹងពីព្រឹត្តិការណ៍ផ្សេងៗដែលកើតឡើងនៅក្រសួង និងនៅសាលារបស់កូន តាមរយៈការប្រើវ៉ិបសៃ ដែលអនុញ្ញាតឲ្យពួកគាត់ផ្តល់ព័ត៌ សម្រាប់ឲ្យគេទាក់ទងដែលមានការកែប្រែមានថ្មីៗ ជ្រើសរើសវិធីឲ្យគេទាក់ទងដែលងាយស្រួលដល់ពួកគាត់ (ផ្ញើសារតាមទូរស័ព្ទដៃ/texting ទូរស័ព្ទ ឬ អ៊ីមែល) ចុះឈ្មោះដើម្បីទទួលដំណឹងថ្មីៗពីកម្មវិធីអ្វីមួយដែលពួកគាត់ចាប់អារម្មណ៍ ព្រមទាំងមានលទ្ធភាព អាចតាមដាន វត្តមានអវត្តមាន និង ពិន្ទុ របស់កូន តាមអ៊ិនធ័រណិត។
- ផ្តល់វិធីផ្សេងៗដែល មាតាបិតា និង សហគមន៍ អាចប្រើដើម្បីយកព័ត៌មាន និងទទួលជំនួយ ក្នុងការដោះស្រាយការបារម្ភរបស់ពួកគាត់ តាមរយៈ៖
    - មជ្ឈមណ្ឌលទទួលទូរស័ព្ទ និងមជ្ឈមណ្ឌលផ្តល់ព័ត៌មាន របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ទូរស័ព្ទលេខ ២១៥-៤០០-៤០០០ ដែលផ្តល់ព័ត៌មានអំពី ការបម្រើ ផែនការថ្មីៗ និង កម្មវិធី របស់ក្រសួង សម្រួលការទាក់ទងរវាង អតិថិជន និង ការិយាល័យរបស់ក្រសួងនិងធ្វើកិច្ចការជាមួយ សាលា និង បណ្តាញសិក្សា (Learning Networks) ដោយផ្ទាល់ ដើម្បីដោះស្រាយ សំណួរ និង ការបារម្ភ របស់មាតាបិតា តាមរយៈនៃការចាត់ចែងការគាំទ្រមួយទល់មួយ

- ○ មជ្ឈមណ្ឌលផ្តល់ជំនួយសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ ផ្តល់ជំនួយដល់មាតាបិតាដោយផ្ទាល់ ក្នុងការដោះស្រាយការបារម្ភ និង ស្វែងរកវិធីផ្សេងៗ ដើម្បីជួយដល់ការអប់រំរបស់កូនឲ្យកាន់តែប្រសើរឡើង ជួយមាតាបិតារកមើលអ្វីៗនៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្យ៉ា។ ផ្តល់ព័ត៌មានអំពី ច្បាប់ នីតិវិធី កម្មវិធី និង ការបម្រើ។ ចែកជូនព័ត៌មានអំពី កម្មវិធី និង ជំនួយ នៅតាមសហគមន៍ និងផ្តល់ សិក្ខាសាលា និង កម្មវិធី ផ្សេងៗ សម្រាប់មាតាបិតា។
- ○ អ្នកធ្វើទំនាក់ទំនងជាមួយមាតាបិតា ដែលមានមុខនាទីជាច្រើន រួមមាន ការជួយសាលាក្នុងការពង្រីកឱកាសឲ្យមាតាបិតាចូលរួម និងពង្រឹងការសហការរវាងសាលានិងក្រុមគ្រួសារ ជួយមាតាបិតាក្នុងការដោះស្រាយការបារម្ភរបស់ពួកគាត់ តាមរយៈនៃការចាត់ចែងការគាំទ្រមួយទល់មួយ ធ្វើជាអ្នកទាក់ទង ឲ្យ ការិយាល័យកណ្តាល/បុគ្គលិកសាលា និង ក្រុមគ្រួសារ ប្រមូលព័ត៌មានដែលគេចែកចាយ អំពី ការបម្រើ និង ជំនួយផ្សេងៗ រៀបចំ និង ជួយសម្រួល សិក្ខាសាលា និង ពិពរណ៍ផ្តល់ព័ត៌មាន សម្រាប់មាតាបិតា ជួយសាលាបង្កើត ក្រុមប្រឹក្សាសាលា និងផ្តល់ការបម្រើ និង ជំនួយ ផ្សេងៗទៀត ឲ្យត្រូវតាមសេចក្តីត្រូវការខុសៗគ្នា របស់ក្រុមគ្រួសារទាំងអស់។

- ប្រើអង្គប្រជុំស្តីអំពី វិធីសាស្ត្រ ច្បាប់ និង អ្វីៗដែលសំខាន់ របស់គណកម្មាធិការកែទម្រង់សាលារៀន ដើម្បីទាក់ទងទៅក្រុមអ្នកសំខាន់ៗទាំងអស់ រួមទាំង មាតាបិតា សិស្សានុសិស្ស បុគ្គលិក និង សហគមន៍ ដើម្បីទទួលយោបល់ ទទួលគំនិតថ្មីៗ និងសុំកែប្រែ ច្បាប់ និង អ្វីៗដែលសំខាន់ របស់ក្រសួង។

- ពង្រឹងការចូលរួមរបស់ ក្រុមគ្រួសារ និងសហគមន៍ ក្នុងការសម្រេចផែនការនៅតាមសាលា តាមរយៈនៃការបង្កើតឲ្យមាន ក្រុមប្រឹក្សាសាលា ទូទាំងក្រសួង – គឺជាក្រុមប្រឹក្សាដែលតំណាងឲ្យទូទាំងសាលា នៅពេលមានការ ពិភាក្សាពីរឿងដែលប៉ះពាល់ដល់សាលាទាំងមូល។ នាំឲ្យមានការជួបជុំគ្នាក្នុងចំណោមអ្នកតំណាងពីក្រុមសំខាន់ៗទាំងអស់ ដែលមិត្តភ័ក្តបានបោះឆ្នោតឲ្យះ មាតាបិតា (ដែលមានសម្លេងភាគច្រើននៅក្នុង ក្រុមប្រឹក្សាសាលា (SAC)) ក្រុមអ្នកដឹកនាំរបស់ សាលា និង បុគ្គលិក ដៃគូនៅក្នុងសហគមន៍ និង សិស្សានុសិស្ស (សម្រាប់វិទ្យាល័យ)។ SACs ផ្តល់វេទិកាសម្រាប់ ការពិភាក្សា និង ការសហការ ដើម្បីធ្វើយ៉ាងណាឲ្យសិស្សានុសិស្សទាំងអស់ទទួលបានជោគជ័យ។

- ធ្វើយ៉ាងណាឲ្យក្រុមគ្រួសារដែលនិយាយភាសាចម្រុះ មានលទ្ធភាពទទួល ព័ត៌មាន ជំនួយ និង ឱកាសដែលមាតាបិតាអាចចូលរួម តាមរយៈ៖
  - ○ មជ្ឈមណ្ឌលបកប្រែភាសារបស់ក្រសួងអប់រំ ផ្តល់ការបម្រើ និងជំនួយ ដើម្បីជួយសម្រួលដល់ការទាក់ទងជាមួយក្រុមគ្រួសារ ដែលនិយាយភាសាចម្រុះ រួមទាំង លទ្ធភាពទទួលការបម្រើផ្នែកបកប្រែភាសាតាមទូរស័ព្ទ ជាង១៧០ភាសា ការបកប្រែឯកសាររបស់ក្រសួងទាំងមូល និង របស់សាលានីមួយៗ រក្សាទុកឯកសារដែលបានបកប្រែនៅក្នុងអ៊ិនធ័រណិត និងរៀបចំទំព័រវិបសែសម្រាប់មាតាបិតា និងសហគមន៍ ជាប្រាំបួនភាសា ដែលជាភាសាដែលគេប្រើច្រើនជាងគេនៅក្នុងក្រសួង (អេស្ប៉ាញ៉ុល ចិន អារ៉ាប់ វៀតណាម បារាំង ខ្មែរ រុស្ស៊ី អាល់បានី ណេប៉ាល់)។
  - ○ ការិយាល័យផ្នែកគាំទ្រក្រុមគ្រួសារដែលនិយាយភាសាចម្រុះ ជួយក្រុមគ្រួសារដែលនិយាយភាសាចម្រុះឲ្យមានទំនាក់ទំនង ជាមួយសាលាជាបន្ត ទទួលព័ត៌មាននិងជំនួយរបស់ក្រសួង ជាភាសាកំណើត តាមរយៈនៃការបម្រើរបស់អ្នកជំនួយការផ្នែកផ្តល់ឱវាទនៅសាលាដែលចេះពីរភាសា ផ្តល់ការបកប្រែផ្ទាល់ នៅពេល ជួបជាមួយមាតាបិតា ប្រជុំ កម្មវិធីនៅក្រសួង និង នៅតាមសាលា បង្កើតការសហការជាមួយអង្គការដែលបម្រើ ជនអន្តោប្រវេសន៍ និងជនភៀសខ្លួន និងជួយដល់ក្រុមគ្រួសារ តាមរយៈនៃសិក្ខាសាលា និង ការហ្វឹកហ្វឺន សម្រាប់ក្រុមគ្រួសារ អន្តោប្រវេសន៍ និង ជនភៀសខ្លួន ដែលហៅថា *Welcome Wagons*។ កម្មវិធី Welcome wagons ធ្វើឡើងនៅតាមសហគមន៍ តាមពេលវេលាដែលមានការងាយស្រួលដល់ មាតាបិតា និង ជាភាសាកំណើតរបស់ពួកគាត់។ កម្មវិធីនេះលើកឡើងពីប្រធានបទខុសៗគ្នា ហើយដែលមានសារៈសំខាន់ចំ ពោះសហគមន៍អន្តោប្រវេសន៍ ដែលរួមមាន អក្សរសិល្ប៍ វិធីដាក់ពាក្យសុំចូលរៀននៅមហាវិទ្យាល័យ និងប្រភពនៃជំនួយប្រាក់បង់ថ្លៃ

សាលា សុវត្ថិភាពនៅកន្លែងធ្វើការ លទ្ធភាពនៃការទទួលអត្ថប្រយោជន៍ផ្នែកសុខភាព ការគ្រប់គ្រងលើរោគហឺត វិធីការពារមេរោគ អេចអាយវី (HIV) ការផ្លាស់ប្តូរជីវិតរស់នៅនៅសហរដ្ឋ ការផ្លាស់ប្តូរប្រពៃណីវប្បធម៌ និងបញ្ហារវាង មាតាបិតា និង កូន របៀបចិញ្ចឹមកូន និងការប្រៀនប្រដៅ ដឹង និង ការស្វែងរក ការព្យាបាលនៃសេចក្តីទុក្ខព្រួយ ដឹងពីអំពើហឹង្សានៅក្នុងគ្រួសារ និងការពារ ការធ្វើបាបក្មេង។

- ធ្វើការយ៉ាងជិតស្និតជាមួយ មាតាបិតាដែលជាអ្នកដឹងនាំ ក្រុមគ្រួសារ និងអ្នកសំខាន់ៗនៅក្នុងសហគមន៍ ដើម្បីបង្កើនការយល់ដឹងពីសារៈសំខាន់ នៃការចូលរួមរបស់ពួកគាត់នៅតាម សាលា និង ក្រសួង ហើយជំរុញឲ្យពួកគាត់ ខិតខំកសាងទំនាក់ទំនងជាមួយ គ្រូ នាយកសាលា និង បុគ្គលិកនៅតាមសាលា ចូលរួមក្នុងយប់ជួបប្រជុំជាមួយបុគ្គលិកសាលាដំបូង (Back to School Nights) និងអង្គប្រជុំរវាង មាតាបិតា និង គ្រូ រក្សាការទាក់ទងជាមួយសាលា ទៅមើលថ្នាក់រៀនរបស់កូន ចូលរួមក្នុង អង្គប្រជុំ និង កម្មវិធីផ្សេងៗ នៅសាលា ស្ម័គ្រចិត្ត ចូលរួមក្នុងក្រុមមាតាបិតា និងដើរតួជាអ្នកដឹកនាំឡើងវិញ។

## <u>ផ្នែកទី II</u> <u>សេចក្តីតម្រូវនៃលក្ខន្តិកៈ</u>

**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** យល់ព្រមអនុវត្តសេចក្តីតម្រូវនៃលក្ខន្តិកៈ ដូចតទៅនេះ៖

- ក្រសួងអប់រំនឹងចាប់ផ្តើមប្រតិបត្តិនូវ កម្មវិធី សកម្មភាព និង វិធីសាស្ត្រផ្សេងៗ សម្រាប់ការចូលរួមរបស់មាតាបិតា នៅតាមសាលាទាំងអស់របស់ក្រសួង ដែលស្របទៅតាមមាត្រាលេខ១១១៨ នៃច្បាប់អប់រំនៃថ្នាក់ បឋមសិក្សា និង មធ្យមសិក្សា (ESEA) កម្មវិធី Title I, Part A។ កម្មវិធី សកម្មភាព និង វិធីសាស្ត្រ ទាំងនោះ នឹងត្រូវបានគេ រៀបចំ និង អនុវត្ត ដោយមានការពិគ្រោះពិភាក្សាដ៏មានអត្ថន័យជាមួយនឹងមាតាបិតា របស់ក្មេងដែលចូលរួម។
- ស្របតាមមាត្រាលេខ១១១៨ ក្រសួងអប់រំនឹងសហការជាមួយសាលាទាំងអស់របស់ក្រសួង ដើម្បីធ្វើយ៉ាងណាឲ្យច្បាប់នៃការចូលរួមរបស់មាតាបិតានៅតាមសាលាដែលគេបានតម្រូវ ត្រូវតាមការតម្រូវរបស់មាត្រាលេខ១១១៨(b) នៃច្បាប់ ESEA ហើយការចូលរួមនីមួយៗ មានសមាសភាគនៃកិច្ចសន្យា រវាងមាតាបិតា និង សាលា ដែលស្របតាមមាត្រាលេខ១១១៨(d) នៃច្បាប់ ESEA។
- ការអនុវត្តន៍ច្បាប់ Title I, Part A សេចក្តីតម្រូវនៃការចូលរួមរបស់មាតាបិតា តាមតែអាចធ្វើទៅបាន ក្រសួងអប់រំ និងសាលាទាំងអស់ នឹងផ្តល់ឱកាសចូលរួមយ៉ាងពេញលេញដល់មាតាបិតាដែលចេះភាសាអង់គ្លេសតិចតួច មាតាបិតាដែលពិការ និងមាតាបិតារបស់ក្មេងដែលផ្លាស់ប្តូរទីលំនៅទៅតាមរដូវធ្វើការងារ រួមទាំងការផ្តល់ព័ត៌មាន និងរបាយការណ៍សាលា ដែលបានតម្រូវដោយមាត្រាលេខ១១១៨ នៃច្បាប់ ESEA តាមរបៀបដែលអាចយល់ និងទ្រង់ទ្រាយដូចគ្នា ហើយរួមទាំងតាមទ្រង់ទ្រាយផ្សេងទៀតទៅតាមការស្នើសុំ និងតាមការដែលអាចធ្វើទៅបាន ជាភាសាដែលមាតាបិតា អាចយល់បាន។
- ក្រសួងអប់រំនឹងធ្វើការជាមួយមាតាបិតារបស់ក្មេងដែលទទួលជំនួយពី Title I, Part A នៅសាលា ក្នុងការសម្រេចពីវិធីចំណាយប្រាក់ជំនួយ១ភាគរយនៃ Title I, Part A ដែលទុកសម្រាប់ចំណាយលើការចូលរួមរបស់មាតាបិតា និង ក្រុមគ្រួសារ ហើយនឹងធ្វើយ៉ាងណាមិនឲ្យតិចជាង៩៥ភាគរយ នៃប្រាក់ជំនួយ១ភាគរយនេះ ត្រូវឲ្យទៅសាលាដោយផ្ទាល់ សម្រាប់ចំណាយទៅលើសកម្មភាពផ្សេងៗដែលទាក់ទងនឹងមាតាបិតា ដូចកិច្ចព្រមព្រៀងរវាង មាតាបិតា និងរដ្ឋបាលសាលា ដោយមានការយល់ព្រមពី គណៈកម្មាធិការកែទម្រង់សាលារៀន (SAC)។

- ក្រសួងអប់រំស្ថិតនៅក្រោមនិយមន័យនៃលក្ខន្តិកៈនៃការចូលរួមរបស់ក្រុមគ្រួសារ ដូចតទៅនេះ ហើយសង្ឃឹមថាសាលាទាំងអស់ដែលនៅក្រោមច្បាប់ Title I នឹងអនុវត្ត កម្មវិធី សកម្មភាព និង វិធីផ្សេងៗ ស្របទៅតាមនិយមន័យនេះ៖

*ការចូលរួមរបស់ មាតាបិតា និងក្រុមគ្រួសារ មានន័យថា ជាការចូលរួមជាប្រចាំរបស់មាតាបិតា ទៅវិញទៅមក និងជាទំនាក់ទំនងដែលមានអត្ថន័យ ដែលពាក់ព័ន្ធនឹងការសិក្សារបស់សិស្សានុសិស្ស និងសកម្មភាពសាលាផ្សេងៗទៀត រួមទាំងការធ្វើយ៉ាងណាឲ្យ—*

(ក) *មាតាបិតា មានតួនាទីដ៏សំខាន់ ក្នុងការជួយដល់ការសិក្សារបស់កូន*

(ខ) *មាតាបិតា ត្រូវទទួលការលើកទឹកចិត្តឲ្យចូលរួមយ៉ាងសកម្មក្នុងការសិក្សារបស់កូននៅសាលា*

(គ) *មាតាបិតា ជាដៃគូយ៉ាងពេញទំហឹងក្នុងការសិក្សារបស់កូន និងក្នុងស្ថានភាពសមរម្យ រួមទាំង ក្នុងការសម្រេចចិត្តនិងជាសមាជិកក្រុមប្រឹក្សាដើម្បីជួយដល់ការសិក្សារបស់កូន*

(ឃ) *ធ្វើសកម្មភាពផ្សេងៗ ដូចជាអ្វីៗដែលបានរៀបរាប់នៅក្នុងមាត្រាលេខ១១១៨ នៃច្បាប់ ESEA។*

## ផ្នែកទី III ការរៀបរាប់អំពីវិធីដែលក្រសួងអប់រំនឹងអនុវត្តការតម្រូវនៃផ្នែកផ្សេងៗ របស់ច្បាប់នៃការចូលរួមរបស់ មាតាបិតា និង ក្រុមគ្រួសារ ទូទាំងក្រសួង

១. ក្រសួងអប់រំនៃទីក្រុងហ៊ីឡាដែលហ្វ៊ា នឹងអនុវត្តនូវអ្វីៗដូចខាងក្រោមនេះដើម្បីឲ្យមាតាបិតា ចូលរួមក្នុងការអភិវឌ្ឍន៍រួមគ្នា នូវគម្រោងការនៃការចូលរួមរបស់មាតាបិតាទូទាំងក្រសួង ក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA៖

- គេនឹងសុំឲ្យសាលារបស់ក្រសួងទាំងអស់ ចាត់យ៉ាងហោចណាស់សមាជិកនៃក្រុមគ្រួសារម្នាក់ ឲ្យចុះឈ្មោះជាមួយក្រុមអនុវត្តការងារ នៃការធ្វើទំនាក់ទំនងជាមួយក្រុមគ្រួសារ និង សហគមន៍/Family and Community Engagement Action Team (FACE-A-Team) របស់ក្រសួង ដើម្បីចូលរួមក្នុងការហ្វឹកហ្វឺន និងពាំនាំយកព័ត៌មានត្រឡប់ទៅសាលារបស់ពួកគាត់វិញ។
- គេនឹងសុំឲ្យសមាជិកនៃ ក្រុម FACE-A-Team ផ្តល់យោបល់សម្រាប់ ច្បាប់ និង ផែនការ នៃការធ្វើទំនាក់ទំនងជាមួយក្រុមគ្រួសារ និងសហគមន៍ របស់ក្រសួងអប់រំ នៅពេលមានប្រជុំ ទូទាំងក្រសួង ឬ នៅតាមតំបន់។
- ក្រសួងអប់រំនឹងផ្ញើសេចក្តីណែនាំ (ដែលបានចុះហត្ថលេខាដោយ អគ្គនាយក) ទៅ អគ្គនាយករង និង នាយកសាលា អំពីការផ្សព្វផ្សាយច្បាប់របស់ក្រសួង ជូនទៅមាតាបិតា។
- ច្បាប់កែប្រែថ្មីៗនឹងមាននៅក្នុងអ៊ិនធ័រណិត សម្រាប់ឲ្យមាតាបិតា ធ្វើការពិនិត្យ និង ផ្តល់យោបល់។
- លិខិតសម្រាប់មាតាបិតាដែលផ្ញើភ្ជាប់មកជាមួយនឹងច្បាប់នេះ នឹងផ្តល់ដំណឹងដល់មាតាបិតាអំពីវិធីបន្ថែម សម្រាប់ការផ្តល់មតិយោបល់ រួមទាំងការដាក់ស្នើយោបល់របស់ពួកគាត់តាមរយៈការស្ទង់មតិតាមអ៊ិនធ័រណិត តាមទូរស័ព្ទ ឬតាមរយៈការចូលរួមក្នុងអង្គប្រជុំរបស់ក្រុម FACE-A-Team នៅតាមតំបន់របស់ពួកគាត់។

២. ក្រសួងអប់រំនៃទីក្រុងហ៊ីឡាដែលហ្វ៊ា នឹងមានសកម្មភាពដូចខាងក្រោមនេះដើម្បីឲ្យមាតាបិតាចូលរួមក្នុងវិធីពិនិត្យ និងកែលម្អសាលាក្រោមមាត្រាលេខ១១១៦ នៃច្បាប់ ESEA៖

- ដល់ ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៥ យ៉ាងហោចណាស់៥០% នៃសាលារបស់ក្រសួងអប់រំ នឹងមានក្រុមប្រឹក្សាសាលា (SAC) ដែលរួមមាន មាតាបិតា សិស្សានុសិស្ស[1] រដ្ឋបាលសាលា បុគ្គិល និងដៃគូនៅក្នុងសហគមន៍ ដែលក្រុមមាតាបិតាធំជាងគេ នៅក្នុងក្រុមប្រឹក្សាសាលា[2]។ ការទទួលខុសត្រូវចម្បងរបស់ក្រុមប្រឹក្សាសាលា គឺការផ្តល់យោបល់សម្រាប់ផែនការ និងថវិការបស់សាលា។
- អ្នកតំណាងរបស់ក្រសួង នឹងរួមសហការជាមួយអ្នកដឹកនាំមាតាបិតា និងបុគ្គលិកនៃការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ ដើម្បីផ្តល់ការហ្វឹកហ្វឺនដល់ ក្រសួង តាមតំបន់ និង/ឬ តាមសាលា អំពីចំណុចផ្សេងៗរបស់ច្បាប់ Title I រួមទាំងការយល់ដឹងពី ទិន្នន័យ ផែនការសាលា និង វិធីប្រើថវិកា។
- គេនឹងផ្តល់ការហ្វឹកហ្វឺនផ្អែកការងារដល់ ក្រុមប្រឹក្សាសាលា (បុគ្គលិកសាលា សិស្សានុសិស្ស ក្រុមគ្រួសារ និង ដៃគូនៅក្នុងសហគមន៍) ដើម្បីជួយឲ្យយល់អំពី តួនាទី និងការទទួលខុសត្រូវ របស់ភាគីទាំងអស់ នៅក្នុងវិធីនេះ។
- មជ្ឈមណ្ឌលបកប្រែភាសា និងការិយាល័យផ្តល់ជំនួយដល់ក្រុមគ្រួសារដែលនិយាយភាសាចម្រុះ របស់ក្រសួង នឹងផ្តល់ជំនួយផ្អែកភាសាដល់ មាតាបិតាដែលភាសាទីមួយមិនមែនជាភាសាអង់គ្លេស។

៣. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នឹងផ្តល់ការរៀបចំដ៏ចាំបាច់ដូចតទៅនេះ ជំនួយបច្ចេកទេស និងជំនួយផ្សេងៗ ដើម្បីជួយសាលាដែលទទួលជំនួយពីច្បាប់ Title I, Part A ក្នុងការរៀបគម្រោង និង ការអនុវត្តន៍សកម្មភាពដែលមានប្រសិទ្ធិភាព នៃការចូលរួមរបស់មាតាបិតា ដើម្បីបង្កើនជោគជ័យនៃ ការសិក្សារបស់សិស្សានុសិស្ស និង ការអប់រំរបស់សាលា៖

- តាមការសហការជាមួយក្រុមមាតាបិតា ផ្តល់សិក្ខាសាលាដល់សាលាអំពីការចូលរួមរបស់មាតាបិតា។
- តាមរយៈសាកលវិទ្យាល័យមាតាបិតា ផ្តល់ការហ្វឹកហ្វឺនដល់មាតាបិតា រួមមាន តែគ្មានកំណត់ ដូចជា ការត្រៀមខ្លួនប្រឡង ការអាន គណិតវិទ្យា វិទ្យាសាស្ត្រ PSSA និង Keystone។
- ផ្តល់សិក្ខាសាលាដល់មាតាបិតាអំពី សន្តិសុខនៅសាលា ប្រពៃណីវប្បធម៌ចម្រុះ ដំណោះស្រាយជម្លោះ វិធីនៃការចូលរួមរបស់មាតាបិតា និងប្រធានបទផ្សេងៗទៀត តាមការស្នើសុំ។
- ហ្វឹកហ្វឺនមាតាបិតាដែលនៅក្នុងក្រុម FACE-A-Team ឲ្យធ្វើជាអ្នកទាក់ទងឲ្យ នាយកសាលា និងក្រុមប្រឹក្សាសាលា (SACs) សម្រាប់ផែនការដែលមានលើកឡើងនៅ តាមថ្នាក់ក្រសួងអប់រំ និង តាមបណ្តាញ នានា។
- ដើម្បីឲ្យស្របតាម គម្រោងផែនការនៃការអនុវត្តន៍ ២,០ (Action Plan 2.0) របស់ក្រសួង ជំរុញឲ្យ មាតាបិតា និង ក្រុមគ្រួសារ មានឱកាសជួប គ្រូ និង នាយកសាលា។

៤. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នឹងរៀបចំ ព្រមទាំងរួមបញ្ចូល វិធីសាស្ត្រនៃការចូលរួមរបស់មាតាបិតានៅក្នុងច្បាប់ Title I, Part A ជាមួយនឹង វិធីសាស្ត្រនៃការចូលរួមរបស់មាតាបិតានៅក្នុងកម្មវិធីផ្សេងៗ ដូចតទៅនេះ៖ កម្មវិធី Head Start អនាគតភ្លឺស្វាង (Bright Future) និង កម្មវិធី ELECT ដោយ៖

- បង្កើនការសហការរវាងបុគ្គលិកនៃ កម្មវិធីមុនថ្នាក់មត្តេយ្យ និង កម្មវិធី ELECT ចំពោះការទទួលខុសត្រូវនៃការចូលរួមរបស់មាតាបិតា និង ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍។
- អញ្ជើញមាតាបិតារបស់សិស្សថ្នាក់មុនមត្តេយ្យ មកចូលរួមក្នុង អង្គប្រជុំ កម្មវិធី និងសកម្មភាព ផ្សេងៗរបស់ក្រសួង។
- ផ្តល់ការបកប្រែភាសាសម្រាប់កម្មវិធីមុនថ្នាក់មត្តេយ្យដល់ក្រុមគ្រួសារដែលភាសាអង់គ្លេសមិនមែនជាភាសាកំណើត។

---

[1] តម្រូវឲ្យមានសិស្សចូលរួមនៅវិទ្យាល័យ

[2] នៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ មាតាបិតាមានចំនួន៥១% នៃចំនួនពី ៧ ទៅ ២១ កៅអី នៅក្នុងក្រុមប្រឹក្សាសាលា។ នៅវិទ្យាល័យ ចំនួនទាបបំផុត ៥១% ដែលគេអាចបោះឆ្នោតឲ្យ នៅក្នុងក្រុមប្រឹក្សាសាលា គឺត្រូវចែកគ្នារវាង មាតាបិតា និងសិស្សានុសិស្ស ដែលមានមាតាបិតាយ៉ាងហោចណាស់២កៅអី នៃចំនួនសិស្សមួយកៅអី ចំនួនតិចបំផុតគឺ មាតាបិតា៦នាក់ សិស្ស៣នាក់។

៥. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នឹងធ្វើការស្ទង់មតិ មាតាបិតា និងអាណាព្យាបាល ប្រចាំឆ្នាំ ដើម្បីប្រមូលទិន្នន័យអំពី លទ្ធផលនៃការចូលរួមរបស់មាតាបិតា នៅតាមសាលា និងទូទាំងក្រសួង ហើយនឹងទាក់ទងទៅមាតាបិតាដើម្បីសុំយោបល់ពីគាត់ នៅពេលរៀបចំការស្ទង់មតិ និង វិធីវាយតម្លៃ។

គេនឹងប្រើលទ្ធផលនៃការស្ទង់មតិ ដើម្បីរកមើលឧបសគ្គដែលរារាំងមិនឲ្យមាតាបិតាចូលរួមបានច្រើន ក្នុងសកម្មភាពនៃការចូលរួមរបស់មាតាបិតា (ជាពិសេសយកចិត្តទុកដាក់ទៅលើ មាតាបិតាដែលក្រីក្រ ពិការភាព ចេះភាសាអង់គ្លេសតិចតួច មានការអប់រំតិចតួច ឬ ជាសាសន៍ ឬជនជាតិភាគតិច)។ ក្រសួងអប់រំនឹងប្រើលទ្ធផលនៃការវាយតម្លៃអំពីច្បាប់នៃការចូលរួម និងសកម្មភាពរបស់មាតាបិតារបស់ក្រសួង ដើម្បីរៀបវិធីសាស្ត្រនៃការចូលរួមរបស់មាតាបិតា ឲ្យកាន់តែមានប្រសិទ្ធិភាព និងដើម្បីធ្វើការកែសម្រួលច្បាប់នៃការចូលរួមរបស់មាតាបិតាឡើងវិញ បើសិនជាចាំបាច់ (និងដោយការចូលរួមពីសំណាក់មាតាបិតា)។

៦. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នឹងអនុវត្តនូវសកម្មភាពដូចតទៅ ដើម្បីកសាងសមាសភាពនៃការចូលរួមរបស់ សាលា និងមាតាបិតាឲ្យបានរឹងមាំ ដើម្បីធ្វើយ៉ាងណាឲ្យការចូលរួមរបស់មាតាបិតាមានប្រសិទ្ធភាព និងជួយដល់ចំណងមិត្តភាពក្នុងចំណោមសាលាដែលបានចូលរួម មាតាបិតា និងសហគមន៍ ដើម្បីកែលម្អការរីកចម្រើននៃការសិក្សារបស់សិស្ស៖

ក. ដោយមានជំនួយពីការិយាល័យផ្សេងៗរបស់ក្រសួង ក្រសួងអប់រំ នឹងអនុវត្តសកម្មភាពដូចតទៅនេះ ដើម្បីផ្តល់ជំនួយដល់មាតាបិតារបស់ក្មេងដែលទទួលការបម្រើពីក្រសួងអប់រំ ឬ ពីសាលា ក្នុងការយល់ដឹងអំពីប្រធានបទដូចតទៅ៖

– មុខវិទ្យាសិក្សាតាមខ្នាតគំរូរបស់រដ្ឋ
– ជោគជ័យនៃការសិក្សារបស់សិស្សតាមខ្នាតគំរូរបស់រដ្ឋ
– ការវាយតម្លៃការសិក្សារបស់រដ្ឋ និងតំបន់ រួមទាំងការវាយតម្លៃតាមវិធីផ្សេងទៀត
– ការតម្រូវរបស់ច្បាប់ Title I, Part A
– វិធីតាមដានការរីកចម្រើនរបស់ក្មេង និង
– វិធីធ្វើការជាមួយអ្នកអប់រំ។

- ការិយាល័យផ្នែករកប្រាក់ជំនួយ និង ធ្វើតម្រូវការ/ច្បាប់ Title I នឹងរង់ចាំសហការជាមួយការិយាល័យផ្សេងៗ និងក្រុមមាតាបិតា ដើម្បីផ្តល់ការពន្យល់ណែនាំ និងសិក្ខាសាលា អំពីការតម្រូវនៃច្បាប់ Title I និងសិទ្ធិដែលត្រូវដឹងរបស់មាតាបិតា នៅក្រោមច្បាប់អប់រំនៃ សាលាបឋមសិក្សា និងមធ្យមសិក្សា។
- សំណូមពរសុំឲ្យនាយកសាលារួមបញ្ចូលមាតាបិតានៅថ្ងៃហ្វឹកហ្វឺនបុគ្គលិកនៅតាមសាលា នៅពេលណាដែលមានលក្ខណៈសមរម្យ។
- ឧបត្ថម្ភ និងជំរុញ សាលាឲ្យគាំទ្រដល់ការចូលរួមរបស់មាតាបិតា ក្នុងអង្គប្រជុំ និងសិក្ខាសាលាផ្សេងៗ ដូចជា អង្គប្រជុំក្រុមប្រឹក្សាមាតាបិតាប្រចាំឆ្នាំរបស់រដ្ឋ អង្គប្រជុំអំពីការចូលរួមរបស់ក្រុមគ្រួសារប្រចាំឆ្នាំ (ការរួបរួមសម្រាប់ការចូលរួមរបស់ក្រុមគ្រួសារនៃរដ្ឋផិនស៊ីលវេញ៉ា) និងអ្វីៗផ្សេងទៀត។
    - តម្រូវឲ្យមាតាបិតាដែលមានបំណងចង់ចូលរួមក្នុងអង្គប្រជុំមាតាបិតា ឲ្យបញ្ជាក់ថាបានយកការហ្វឹកហ្វឺនទាំងនេះមកធ្វើនៅតាមសាលា និង/ឬ នៅថ្នាក់ក្រសួង។ ការបញ្ជាក់នឹងមាន៖ ១) បញ្ជីចុះហត្ថលេខានៃបេក្ខជនចូលរួម ២) របៀបវារៈ និង ៣) ច្បាប់ចម្លងនៃឯកសារ ដែលបានចែកចាយ។
    - ធ្វើយ៉ាងណាឲ្យមាតាបិតាដែលត្រូវបានគេជ្រើសរើសឲ្យចូលរួមក្នុងអង្គប្រជុំនៃច្បាប់ Title I, PAC តាមថ្នាក់រដ្ឋ ឬថ្នាក់ទូទាំងប្រទេស ត្រូវចូលរួមប្រជុំជាមួយក្រុម FACE-A-Team របស់ក្រសួងឲ្យបានទៀងទាត់ និងផ្តល់របាយការណ៍ (ជាពាក្យសំដី ឬជាលាយលក្ខណ៍អក្សរ)។

- ផ្តល់ព័ត៌មានជូនមាតាបិតា ជាភាសាដែលងាយយល់ និង ច្បាស់លាស់។
- បើអាចធ្វើទៅបាន ផ្តល់សិក្ខាសាលាជាភាសាកំណើតដល់គ្រួសារណាដែលភាសាអង់គ្លេសមិនមែនជាភាសាទី១។
- ចែកជូនមាតាបិតានូវឯកសារពី ការិយាល័យកម្មវិធីសិក្សា និងការបង្ហាត់បង្រៀន និងពីការិយាល័យផ្សេងៗទៀត ដែលមានប្រយោជន៍នៅផ្ទះ រួមទាំងការបកប្រែភាសា តាមការដែលអាចធ្វើទៅបាន។

ខ. ដោយមានជំនួយពីសាលាផ្សេងៗរបស់ក្រសួង ក្រសួងអប់រំនឹងផ្តល់ឯកសារ និងការហ្វឹកហ្វឺនផ្សេងៗ ដើម្បីជួយមាតាបិតាក្នុងការជួយកូនរបស់ពួកគាត់ បង្កើនជោគជ័យក្នុងការសិក្សា ដូចជាសិក្ខាសាលាផ្នែក អក្សរសិល្ប៍ និងបច្ចេកវិទ្យា ទៅតាមលក្ខណៈសមរម្យ។ ដើម្បីជួយឲ្យមាតាបិតាចូលរួម៖

- បង្កើតសាកលវិទ្យាល័យមាតាបិតាទូទាំងក្រុង ដើម្បីផ្តល់ការអប់រំជាច្រើនយ៉ាងជូនដល់មាតាបិតា ដោយបុគ្គលិករបស់ក្រសួងអប់រំ និងក្រុមអ្នកផ្តល់ជំនួយផ្សេងៗទៀត រួមមានទាំង វិធីជួយកូននៅសាលា និងចំណេះដឹងផ្នែកកុំព្យូទ័រ។
- ការគាំទ្រក្នុងការបង្កើត មជ្ឈមណ្ឌល/កាច់ជ្រុង/បន្ទប់ ផ្តល់ព័ត៌មានសម្រាប់មាតាបិតា នៅសាលា។
- ផ្តល់ការហ្វឹកហ្វឺនចំណេះដឹងផ្នែកកុំព្យូទ័រ និងការហ្វឹកហ្វឺនផ្សេងៗទៀត សម្រាប់មាតាបិតា រួមទាំងវិធីប្រើ ទំព័រវិបសែសម្រាប់ មាតាបិតា និងក្រុមគ្រួសារ (Parent and Family portal) ដែលជាមធ្យោបាយតាមដានជោគជ័យរបស់កូននៅសាលា។
- ជួយសាលាក្នុងការរៀបចំផែនការ និង ការអនុវត្តន៍ សកម្មភាពនៅតាមសាលា ដូចជាកម្មវិធីសិក្សា អក្សរសិល្ប៍ និងគណិតវិទ្យា សម្រាប់គ្រួសារនៅពេលយប់ និង សិក្ខាសាលាផ្សេងៗ ដើម្បីជួយមាតាបិតា ឲ្យយល់អំពីវិធីជួយកូនឲ្យទទួលបានជោគជ័យក្នុងការសិក្សា ដោយមានជំនួយពីការិយាល័យផ្សេងៗរបស់ក្រសួង ដែលជាប់ពាក់ព័ន្ធ។
- ផ្តល់ សិក្ខាសាលា និងឯកសារដូចខាងលើនេះតាមលក្ខណៈសមរម្យ ជាភាសាដែលមិនមែនជាភាសាអង់គ្លេស។

គ. ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ អាចផ្តល់ការហ្វឹកហ្វឺនផ្នែកការងារនៅតាមសាលា ដើម្បីអប់រំ គ្រូ បុគ្គលិកធ្វើការជាមួយសិស្ស នាយកសាលា និងបុគ្គលិកផ្សេងៗទៀត អំពីវិធី ទាក់ទង និងធ្វើការជាមួយមាតាបិតា ក្នុងនាមជាដៃគូដែលមានសិទ្ធិស្មើភាពគ្នា ក្នុងការឲ្យតម្លៃ និងការប្រើប្រាស់មតិយោបល់របស់មាតាបិតា និងអំពីវិធី អនុវត្ត និងការចាត់ចែងកម្មវិធីសម្រាប់មាតាបិតា ព្រមទាំងការបង្កើតចំណងមិត្តភាពរវាងមាតាបិតា និងសាលា ដោយ៖

- មានជំនួយពីមាតាបិតា ផ្តល់ឱការហ្វឹកហ្វឺនផ្នែកការងារដល់ នាយកសាលា និងបុគ្គលិករដ្ឋបាលដទៃទៀត អំពីវិធីបង្កើតការសហការជាមួយមាតាបិតា។
- ផ្តល់យោបល់ឲ្យអញ្ជើញ មាតាបិតាទាំងអស់មកចូលរួមពិនិត្យឡើងវិញនូវច្បាប់ Title I នៃការចូលរួមរបស់មាតាបិតានៅសាលា និងកិច្ចព្រមព្រៀងរវាង សាលា និង មាតាបិតា (តាមសេចក្តីត្រូវការ)។

ឃ. តាមតែអាចធ្វើទៅបាន ក្រសួងអប់រំនឹង រៀបចំ និង បញ្ចូល កម្មវិធីនៃការចូលរួមរបស់មាតាបិតា និងសកម្មភាពផ្សេងៗជាមួយនឹងកម្មវិធី Head Start អនាគតភ្លឺស្វាង (Bright Future) កម្មវិធី ELECT និងកម្មវិធីផ្សេងៗទៀត ព្រមទាំងបង្កើតឲ្យមានសកម្មភាព ផ្សេងៗទៀត ដូចជា មណ្ឌលផ្តល់ព័ត៌មានសម្រាប់មាតាបិតា ដែលអាចជួយលើកទឹកចិត្ត និងជួយគាំទ្រឲ្យមាតាបិតាចូលរួមឲ្យបានពេញលេញក្នុងការអប់រំកូនរបស់ពួកគាត់ ដោយ៖

- បង្កើនការសហការរវាងបុគ្គលិកនៃ កម្មវិធីមុនថ្នាក់មត្តេយ្យ និងកម្មវិធី ELECT ដែលទទួលខុសត្រូវចំពោះ ការចូលរួមរបស់មាតាបិតា និង ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍។
- រកមាតាបិតារបស់សិស្សថ្នាក់មុនមត្តេយ្យឲ្យមកចូលរួមប្រជុំ ចូលរួមកម្មវិធី និងសកម្មភាពផ្សេងៗ នៅក្រសួង។

- ផ្តល់ការបកប្រែភាសាសម្រាប់កម្មវិធីមុនថ្នាក់មត្តេយ្យ ជូនដល់ក្រុមគ្រួសារដែលភាសាអង់គ្លេសមិនមែនជាភាសាកំណើត។

ង. ក្រសួងអប់រំនឹងធ្វើសកម្មភាពដូចខាងក្រោមនេះ ដើម្បីធ្វើយ៉ាងណាឲ្យព័ត៌មានដែលទាក់ទងនឹងកម្មវិធី របស់សាលា និង សម្រាប់មាតាបិតា អង្គប្រជុំ និងសកម្មភាពផ្សេងៗទៀត ផ្ញើជូនទៅមាតាបិតាដែលមានកូនរៀននៅក្នុងកម្មវិធីទាំងនោះ ក្នុងលក្ខណៈដែលអាចយល់ និង មានទម្រង់ដូចគ្នា រួមទាំងជាទម្រង់ផ្សេងៗទៀត ទៅតាមការស្នើសុំ និងទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន គឺជាភាសាដែលមាតាបិតាអាចយល់បាន៖

- តាមការដែលអាចធ្វើទៅបាន ផ្តល់ការទាក់ទងជាភាសាដែលងាយយល់ និង ច្បាស់លាស់ ។
- ផ្សព្វផ្សាយព័ត៌មានសម្រាប់ការទាក់ទងជាមួយមាតាបិតា នៅក្នុង វិបសៃ និង ហ្វេសប៊ុក (Facebook) របស់ក្រសួង។
- ធ្វើយ៉ាងណាឲ្យ ព័ត៌មានសម្រាប់ការទាក់ទងជាមួយមាតាបិតា របស់ក្រសួង មានលេខទូរស័ព្ទដែលមាតាបិតាអាចទូរស័ព្ទមកសួរបញ្ជាក់។
- ចែកជូនព័ត៌មានសំខាន់ៗទៅ មណ្ឌលទទួលទូរស័ព្ទ និង មណ្ឌលផ្តល់ព័ត៌មាន របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា លេខ ២១៥-៤០០-៤០០០ អ្នកធ្វើទំនាក់ទំនងជាមួយមាតាបិតា និងអ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា ដើម្បីឲ្យពួកគេអាចចែកជូនព័ត៌មានទាំងនោះទៅក្រុមគ្រួសារ និងផ្តល់ការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីព័ត៌មានសម្រាប់ការប្រាស្រ័យទាក់ទងសំខាន់ៗរបស់ក្រសួង។
- រៀបចំអង្គប្រជុំ និង សិក្ខាសាលា ជាមួយ មាតាបិតា និងសហគមន៍ ដើម្បីលើកឡើងអំពីប្រធានបទសំខាន់ៗ។
- ស្នើសុំដៃគូនៅក្នុងសហគមន៍ រួមមាន បណ្ណាល័យ មណ្ឌលលេងកំសាន្ត សមាគមនៅក្នុងសហគមន៍ និងអង្គការសាសនាផ្សេងៗ ឲ្យជួយផ្សព្វផ្សាយព័ត៌មាន។
- ផ្តល់ការបកប្រែភាសាដល់ក្រុមគ្រួសារដែលភាសាអង់គ្លេសមិនមែនជាភាសាកំណើត ដោយផ្ទាល់ ឬតាមទូរស័ព្ទ ទៅតាមលក្ខណៈសមរម្យ។

## ផ្នែកទី IV ចំណុចផ្សេងៗអំពីការបើកទូលាយនៃច្បាប់ចូលរួមរបស់ មាតាបិតា និងក្រុមគ្រួសារ ទូទាំងក្រសួងអប់រំ

- ឲ្យមាតាបិតាចូលរួមក្នុងការរៀបចំការហ្វឹកហ្វឺន គ្រូ នាយកសាលា និង អ្នកអប់រំផ្សេងៗទៀត ដើម្បីបង្កើនប្រសិទ្ធិភាពនៃការហ្វឹកហ្វឺន
- ផ្តល់ការហ្វឹកហ្វឺនផ្នែកអក្សរសិល្ប៍ដល់មាតាបិតា ទៅតាមលក្ខណៈចាំបាច់ ដែលទទួលជំនួយពីកម្មវិធី Title I Even Start និង Family Literacy
- ទៅតាមចំនួនទឹកប្រាក់ដែលមាន ក្នុងលក្ខណៈសមរម្យ និងចាំបាច់ បង់ថ្លៃការចាយវាយសម្រាប់សកម្មភាពផ្សេងៗដែលទាក់ទងទៅនិងការចូលរួមរបស់មាតាបិតា រួមទាំងការដឹកជញ្ជូន និង ថ្លៃឈ្នួលមើលក្មេង ដើម្បីឲ្យមាតាបិតាមានលទ្ធភាពចូលរួមក្នុងអង្គប្រជុំនៅសាលា និងការហ្វឹកហ្វឺនផ្សេងៗ
- ហ្វឹកហ្វឺនមាតាបិតា ដើម្បីបង្កើនការចូលរួមពីសំណាក់ មាតាបិតា/អាណាព្យាបាល ផ្សេងទៀត
- រៀបចំអង្គប្រជុំនៅសាលាទៅតាមពេលវេលាខុសៗគ្នា ឬជួបប្រជុំនៅផ្ទះរវាង គ្រូ ឬ អ្នកអប់រំដ៏ទៃទៀត ដែលធ្វើការផ្ទាល់ជាមួយក្មេងដែលចូលរួមក្នុងកម្មវិធី និង មាតាបិតា ដែលមិនអាចចូលរួមប្រជុំនៅសាលាបាន ដើម្បីបង្កើនការចូលរួមឲ្យបានកាន់តែច្រើនពីក្រុមគ្រួសារក្នុងការអប់រំរបស់កូន។
- ធ្វើកាស្រាវជ្រាវ ការទទួលយក និងការអនុវត្តន៍ តាមគំរូណាដែលអាចជួយកែលម្អការចូលរួមរបស់មាតាបិតា។

- បង្កើត អ្នកតំណាង និងក្រុមប្រឹក្សាសាលាទូទាំងក្រសួង ដើម្បីផ្តល់យោបល់ចំពោះរឿងរ៉ាវគ្រប់យ៉ាង ដែលទាក់ទងនឹងការចូលរួមរបស់ក្រុមគ្រួសារ ក្នុងកម្មវិធីនៃច្បាប់ Title I, Part A។
- បង្កើតឲ្យមានមុខនាទីសមរម្យ សម្រាប់អង្គការនៅក្នុងសហគមន៍ និងពាណិជ្ជករផ្សេងៗ រួមទាំង អង្គការសាសនា នៅក្នុងសកម្មភាពនៃការចូលរួមរបស់ក្រុមគ្រួសារ និង
- ផ្តល់ជំនួយសមរម្យផ្សេងៗ ដល់សកម្មភាពនៃការចូលរួមរបស់ក្រុមគ្រួសារ តាមមាត្រាលេខ ១១១៨ តាមការស្នើសុំរបស់មាតាបិតា។

## <u>ផ្នែកទី V</u> <u>ការអនុម័ត</u>

ច្បាប់នៃការចូលរួមរបស់ក្រុមគ្រួសារទូទាំងក្រសួងនេះបានបង្កើតឡើងរួមគ្នាជាមួយ និងមានការយល់ព្រម ពីសំណាក់មាតាបិតារបស់ក្មេងដែលចូលរួម ក្នុងច្បាប់ Title I, Part A ដោយមានភស្តុតាងនៅក្នុងអង្គប្រជុំនៅថ្ងៃទី ១៤ ២៣ និង ៣០ ខែមករា, ថ្ងៃទី៦ ខែកុម្ភៈ, ថ្ងៃទី១៥ ខែឧសភា, និង ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៤។

ច្បាប់នេះត្រូវបានអនុម័តដោយ **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ហើយនឹងមានប្រសិទ្ធិភាពសម្រាប់កំឡុងពេលមួយឆ្នាំសិក្សា។ ក្រសួងអប់រំនឹងចែកជូនច្បាប់នេះទៅមាតាបិតាទាំងអស់ នៅ ឬ មុន ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥។

______________________________

*(Signature of Authorized Official/*ហត្ថលេខារបស់អាជ្ញាធរ*)*

______________________________

*(Date/*ថ្ងៃខែ*)*

ឯកសារយោង៖

| | |
|---|---|
| NCLB: | 20 U.S.C. §§ 6316(b)(7), (8) |
| C.F.R. | 34 C.F.R. § 200.36 |
| State School Code: | 24 P.S. § 1-101 *et seq.*, including 24 P.S. §§ 6-693, 6-696 |